48/6

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ៥២
ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣
សាលដីកា
លេខ : ១៦ "ឆ"
ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤

## សាលដីកា

## ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាសវនាការជាសាធារណៈនៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជី**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទៈ**លោក [redacted] លឹមប៊ុល (ចុងបណ្តឹងសាទុក្ខ) អាយុ ៤២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១០៥ ផ្លូវជាតិលេខ ១ ភូមិតាងៅ សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**មេធាវី :** លោក [redacted] តំណាងដោយអាណត្តិ

**ចុងចម្លើយៈ**លោក [redacted] កុកង៉ាន់ (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរនាយកក្រុមហ៊ុនបេសគានហ្គាមេន LTD ទីលំនៅសព្វថ្ងៃផ្ទះលេខ ២៣៣ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

មេធាវី ៖ លោក [redacted] តំណាងដោយអាណត្តិ

<u>អំពីវិវាទៈ</u>-ប្តឹងទាមទារប្រាក់

## <u>អំពីអង្គហេតុ និង ចំណុចវិវាទៈ</u>

### ក-<u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារៈ</u>

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ របស់ដើមចោទឈ្មោះ [redacted] លីមប៊ូល ថា ៖ តាមកិច្ចសន្យាជួលដី និង អាគារ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ ភាគីចុងចម្លើយបានជួលដី និង អាគារលេខ ២៣៣ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ហៅឃ្លាំងបេ ពីខ្ញុំ ក្នុងតម្លៃ ៦៥០០ ដុល្លាក្នុងមួយខែ។ ការបង់ប្រាក់ឈ្នួលរបស់ចុងចម្លើយប្រព្រឹត្តទៅជាធម្មតា។ តែចាប់តាំងពីខែ តុលា ឆ្នាំ ២០០៨ រហូតដល់ខែ មិថុនា ឆ្នាំ ២០០៩ ភាគីចុងចម្លើយមិនបានបង់ប្រាក់ឈ្នួលដែលជាកាតព្វកិច្ចរបស់ខ្លួនមកភាគីខ្ញុំបាទទេ។ ក្រោយមកនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ភាគីចុងចម្លើយបានធ្វើលិខិតទទួលស្គាល់ថា ពិតជានៅជំពាក់ប្រាក់ខ្ញុំបាទចំនួន ៥១.០៥០ដុល្លាអាមេរិកប្រាកដមែន។ ក្រោយពីបានធ្វើលិខិតទទួលស្គាល់បំណុលរួចហើយ ភាគីចុងចម្លើយនៅមិនទាន់ធ្វើការទូទាត់ប្រាក់ឈ្នួលនេះមកភាគីខ្ញុំបាទទេ ទោះបីមានការទាមទារពីខ្ញុំបាទក៏ដោយ ទើបខ្ញុំបាទដាក់ពាក្យបណ្តឹងនេះមកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីអោយសាលាដំបូងរាជធានីភ្នំពេញចេញសាលក្រមឱ្យភាគីចុងចម្លើយសងប្រាក់ឈ្នួលនេះមកខ្ញុំបាទ។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៥៧"ណ" ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ សំរេច ៖**

១-បង្គាប់អោយចុងចម្លើយឈ្មោះ [redacted] កុកង៉ាន់ សងប្រាក់ចំនួន ៤៧.០៥០ដុល្លា(បួនម៉ឺនប្រាំពីរពាន់សូន្យរយហាសិបដុល្លាអាមេរិក) និង ជម្ងឺចិត្ត ៣៥លានរៀល (សាមសិបប្រាំលានរៀល) អោយទៅដើមចោទឈ្មោះ [redacted] លីមប៊ូល ។ការទាមទារប្រាក់ ការទាមទារសុំអោយអនុវត្តបណ្តោះអាសន្ន និង ការទាមទារប្រាក់ជម្ងឺចិត្តលើសពីនេះត្រូវច្រានចោល។

២-ច្រានចោលការទាមទាររបស់មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ។

៣-ប្រាក់ប្រដាប់ក្តីគឺជាបន្ទុករបស់ចុងចម្លើយ។

៤-សាលក្រមនេះបានធ្វើការទាញហេតុផលផ្ទាល់មាត់ នាថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១១ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១១។

*សាលក្រមនេះត្រូវបានឈ្មោះ [redacted] កុកង៉ាន់ ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៣៥ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ ត្រង់ចំណុច នៃសេចក្តីសំរេចទាំងមូល។*

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៦"ក្រVI.វ" ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ សំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ របស់ឈ្មោះ [redacted] កុកង៉ាន់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៥៧"ណ" ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី ១ វាក្យខ័ណ្ឌទី ១ , ចំណុចទី ២ និងទី ៣ ទុកជាបានការ ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយឈ្មោះ [redacted] កុកង៉ាន់ ។

សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ ។ ទុកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

*សាលដីកានេះត្រូវបានឈ្មោះ [redacted] កុកង៉ាន់ ប្តឹងសាទុក្ខតាមបណ្តឹងលេខ ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣ ត្រង់ចំណុច នៃសេចក្តីសំរេចទាំងមូល ។*

**ខ-<u>អំពីសេចក្តីថ្លែងការណ៍របស់គូភាគី</u> :**

**ក្រឡាបញ្ជីអានសារណារបស់លោក តាន់ កុកង៉ាន់**

**អ្នកស្រី [redacted] ធីតា ប្រពន្ធរបស់លោក [redacted] កុកង៉ាន់ ធ្វើសេចក្តីថ្លែងការណ៍ដូចខ្លឹមសារក្នុងសារណារបស់លោក [redacted] កុកង៉ាន់ ។**

**លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ថា :** លិខិតបញ្ជាក់ប្រាក់ជំពាក់ថ្លៃទីតាំង ភាគីខ្លួនសំអាងថា ជាលិខិតចុងក្រោយនៃកិច្ចសន្យាលើកទី ១ ។ ការជូនដំណឹងទៅម្ចាស់ទីតាំង អំពីការជួលបន្ត គឺមិនបានទទួលការឆ្លើយតបវិញទេ ។ កូនក្តីខ្លួនបានបង់ប្រាក់ឈ្នួលរហូត តែពុំទាន់បានទទួលការទូទាត់ថ្លៃតទឹក-ភ្លើងទេ ។ មុនបញ្ចប់កិច្ចសន្យា គឺកូនក្តីខ្លួននៅជំពាក់ដើមចោទតែ ២.៥ខែ ប៉ុណ្ណោះ ។ កូនក្តីខ្លួនជួលទីតាំងនេះពី [redacted] លីមប៉ូល ដូច្នេះគាត់ចង់ជួបតែ [redacted] លីមប៉ូល ប៉ុណ្ណោះ ឯអ្នកស្រី [redacted] ម៉ាលី គ្រាន់តែជាអ្នកទទួលប្រាក់ឈ្នួលប៉ុណ្ណោះ ។ ចំពោះប្រាក់ជំពាក់ពីខែ ០១-០៦ ឆ្នាំ ២០០៩ គឺគ្រាន់តែជាកិច្ចសន្យាដើម្បីបន្តការជួលអាគារតាមកិច្ចសន្យាថ្មីបន្ត តែដើមចោទពុំមានទីតាំងជួលបន្ត និង ពុំមានភស្តុតាងអំពីការទូទាត់ថ្លៃតទឹក-ភ្លើងទេ ។ ពេលកូនក្តីខ្លួនធ្លាក់ក្នុងល្បិចរបស់ខ្លួនហើយ ស្រាប់តែដើមចោទគាត់ធ្វើលិខិតជូនដំណឹងអំពីការបញ្ចប់ការជួលទីតាំងបន្ត ។

ការយល់ឃើញរបស់សាលាដំបូងរាជធានីភ្នំពេញ គឺប៉ះពាល់នឹងមាត្រា ១២៣ ព្រោះតាមពាក្យបណ្តឹងចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ របស់ដើមចោទ ជាការប្តឹងទាមទាររហូតសរយៈពេលនៃកិច្ចសន្យា តែបើអនុវត្តតាមលិខិតជំពាក់ប្រាក់នេះ នោះកិច្ចសន្យាថ្មីជួលបន្តនឹងត្រូវចូលជាធរមានដោយស្វ័យប្រវត្តិ បើពុំមានការជូន

ជណើងបញ្ចប់ការជួល មុនចប់កិច្ចសន្យាចាស់ តែជាក់ស្តែងដើមចោទពុំមានទីតាំងជួលបន្តអោយកូនក្តីខ្លួនទេ ព្រោះថា ដីនេះជាដីរបស់ក្រសួងពាណិជ្ជកម្ម ត្រូវលោកជំទាវ [redacted] ម៉ាលី ជួល ហើយជួលបន្តអោយទៅ ឡូ-លឹមប៉ូល ហើយលោក [redacted] លឹមប៉ូល ជួលបន្តមកអោយលោក [redacted] កុកង៉ាន់ តែដោយលោកជំទាវ [redacted] ម៉ាលី មិនបានបង់ថ្លៃជួលទីតាំងអោយក្រសួងពាណិជ្ជកម្ម ទើបក្រសួងពាណិជ្ជកម្មបានបញ្ចប់ការជួលអោយគាត់។ បច្ចុប្បន្នលោក [redacted] កុកង៉ាន់ បានជួលទីតាំងដដែលពីអ្នកផ្សេង។

**សំណូមពរ :** សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ និង សុំបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ។

**លោក** [redacted] **មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ថា :** ខ្លួនពុំមានអ្វីបន្ថែមលើសេចក្តីថ្លែងការណ៍របស់សហភាគាទេ។

**លោក** [redacted] **មេធាវីតំណាងដោយអាណត្តិអោយដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា :** ការបង់ប្រាក់ឈ្នួលរបស់ចុងចម្លើយគឺមិនទៀតទាត់ទេ បើគាត់បង់ពេញសូមអោយគាត់បង្ហាញឯកសារ។ កិច្ចសន្យាជួលនេះបានចប់សព្វគ្រប់ហើយ ការអះអាងរបស់ចុងចម្លើយថា កិច្ចសន្យាជួលដឹងតែបន្តនោះ គឺមិនពិតទេ។ អំឡុងពេលជួលទីតាំង គឺកូនក្តីខ្លួនបានអនុវត្តកាតព្វកិច្ចពេញលេញ។ ការមិនចុះកិច្ចសន្យាថ្មីអោយគាត់ ព្រោះគាត់សុំចុះថ្លៃឈ្នួល និង ការបង់ប្រាក់ឈ្នួលមិនទៀងទាត់ ទើបមុនចប់កិច្ចសន្យាចាស់ ១ខែ យើងបានធ្វើការទូទាត់គ្នាចប់ហើយ ។ ប្រាក់កក់ ៤ខែ និង ថ្លៃតបណ្តាញអគ្គិសនី គឺបានទូទាត់គ្នារួចហើយ ។ ក្រោយធ្វើលិខិតជំពាក់ប្រាក់ ៥១.០៥០ដុល្លា គឺគាត់បានអនុវត្តហើយ គឺគាត់សងបាន ២.០០០ដុល្លា ពីរដង ហើយក៏ឈប់សងក្នុងខែ ១០ នៅសល់ប្រាក់ជំពាក់ជាង ១.០០០ដុល្លា គឺបានទូទាត់គ្នាចប់សព្វគ្រប់ហើយ ។ចុងចម្លើយក៏គ្មានឯក-សារណាផ្សេងដែរ។

**សំណូមពរ :** សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការទាំងមូល។

**លោក** [redacted] **មេធាវីតំណាងដោយអាណត្តិអោយដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា :** អង្គហេតុនៅសាលាដំបូង និង សាលាឧទ្ធរណ៍ មិនដូចអង្គហេតុនៅតុលាការកំពូលនេះទេ គឺមានអង្គហេតុផ្សេងពាក់ព័ន្ធនឹងប្រវត្តិនៃការជួលអាគារ ។ ចំពោះប្រាក់កក់ និង ថ្លៃតបណ្តាញអគ្គិសនី បានទូទាត់គ្នារួចហើយ គឺនៅសល់តែថ្លៃជួលអគារដែលចុងចម្លើយនៅជំពាក់កូនក្តីខ្លួនចំនួន ៥១.០៥០ដុល្លាអាមេរិកទៀត។

**សំណូមពរ :** សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការទាំងមូល។

**លោកមេធាវី** [redacted] **ថ្លែងការណ៍តប :** នៅក្នុងវិក័យប័ត្រមិនបានបញ្ជាក់ថា ជាបំណុលទូទាត់ចុងក្រោយ + ថ្លៃតបណ្តាញអគ្គិសនី គឺពុំមានភស្តុតាងអំពីការទូទាត់ទេ ។ ដូច្នេះ ការសំរេចរបស់សាលាដំបូងក៏ដូចជាសាលាឧទ្ធរណ៍ដែរ គឺសំរេចដោយពុំបានផ្អែកទៅលើភស្តុតាងទេ។



Scanned with CamScanner

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ និង មេធាវីតំណាងដោយអាណត្តិ របស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] កុកងាន់ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពសាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចអោយចុងចម្លើយសងប្រាក់ចំនួន ៤៧.០៥០ដុល្លាអាមេរិក និង ជម្ងឺចិត្ត ៣៥លានរៀល អោយទៅដើមចោទ ដោយសំអាងលើលិខិតចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ក្នុងន័យថា ចុងចម្លើយបានទូទាត់បំណុលជាមួយដើមចោទរួចរាល់អស់ហើយ នោះជាការមិនត្រឹមត្រូវទេ ពីព្រោះថា លិខិតចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ខាងលើនេះ មិនមែនជាលិខិតទូទាត់បំណុលចុងក្រោយទេ គឺជាលិខិតដែលចុងចម្លើយនៅជំពាក់ថ្លៃជួលទីតាំងតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត ដើមចោទប្តឹងទាមទារប្រាក់ឈ្នួលជួលទីតាំងពីចុងចម្លើយចំនួន ៥១.០៥០ដុល្លាអាមេរិក ដោយគិតចាប់ពីខែ តុលា ឆ្នាំ ២០០៨ ដល់ខែ មិថុនា ឆ្នាំ ២០០៩ តាមពាក្យបណ្តឹងចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ នោះ ជាការប្តឹងទាមទារហួសរយៈពេលនៃកិច្ចសន្យា ។ លើសពីនេះទៀត សាលាឧទ្ធរណ៍ក៏ពុំទាន់បានពិចារណាអំពីខ្លឹមសារនៃប្រការ ៤ និង ប្រការ ៩ នៃកិច្ចសន្យាជួលដី និង អាគារ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ ក៏ដូចជាប្រការ ៣ និង ប្រការ ៤ នៃកិច្ចសន្យាផ្ទេរអគ្គិសនី ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៤ នៅឡើយទេ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៦ "ក្រ VII" ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ដែលបានសំរេចមកនេះ ខុសនឹងគតិច្បាប់ ។

## ហេតុដូចនេះ

## វិ និ ច្ឆ័ យ សេ ច ក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] កុកងាន់ ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ១៦៉ក្រ VIរ៉ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ ទាំងមូល។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៥២ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ។

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់ដើមចោទ ។

៥-សាលដីកានេះជំនុំជំរះ នៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤ និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៤។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ភ្នំពេញ,ថ្ងៃទី២០ ខែ មករា ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ,ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤

ប្រធាន

[redacted]